ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា
លេខ : ០០២ សភណន.

# សេចក្តីណែនាំ
## ស្តីពី
## តួនាទី ភារកិច្ចគណៈកម្មការការពារនិក្ខេបបទសាកល្បងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនគរបាល

យោង : កម្មវិធីអប់រំថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនគរបាល លេខ ០០៤កវអ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤។

បណ្ឌិត្យសភានគរបាលកម្ពុជា សូមធ្វើការណែនាំអំពីតួនាទី ភារកិច្ចរបស់ប្រធាន អនុប្រធាន សមាជិក និងជំនួយការ នៃគណៈកម្មការការពារនិក្ខេបបទសាកល្បង និងមន្ត្រីជំនួយការបច្ចេកទេស នៅក្នុងដំណើរការការពារសាកល្បងសម្រាប់និក្ខេបបទថ្នាក់បណ្ឌិតវិទ្យាសាស្ត្រនគរបាល ជំនាញដឹកនាំបញ្ជាការងារសន្តិសុខ ដូចខាងក្រោម៖

### ១- ភារកិច្ចរបស់ប្រធាននិងអនុប្រធាន

- ណែនាំគោលការណ៍ទូទៅ ស្តីពីការធ្វើបទបង្ហាញដើម្បីការពារនិក្ខេបបទសាកល្បងសម្រាប់និក្ខេបបទថ្នាក់បណ្ឌិត
- អញ្ជើញបេក្ខជនបណ្ឌិតឱ្យឡើងធ្វើបទបង្ហាញក្នុងរយៈពេល៣៥នាទី
- អញ្ជើញសមាជិក ចោទសួរសំណួរទាក់ទងនឹងនិក្ខេបបទរបស់បេក្ខជន
- ធ្វើការវាយតម្លៃ និងដាក់ពិន្ទុដោយប្រើប្រាស់ឧបករណ៍វាយតម្លៃដែលវិទ្យាស្ថានបានរៀបចំ
- ដឹកនាំកិច្ចប្រជុំចង្អៀត ជាមួយសមាជិកគណៈកម្មការការពារនិក្ខេបបទសាកល្បងក្នុងរយៈពេល ១៥-២០នាទី ដើម្បីវាយតម្លៃនិងសម្រេចលើលទ្ធផលនៃការការពារនិក្ខេបបទសាកល្បងរបស់បេក្ខជន
- សម្រេចជាសមូហភាពលើលទ្ធផល **ជាប់** (Pass) ឬ **ត្រូវវាយតម្លៃឡើងវិញ** (Re-examination) **ឬ ធ្លាក់** (Fail)
- ប្រកាសលទ្ធផលនៃការសម្រេចរបស់គណៈកម្មការដល់បេក្ខជនបណ្ឌិត
- អនុប្រធានទទួលជួយប្រធានតាមការប្រគល់សិទ្ធិជូនរបស់ប្រធាន និងទទួលជួយការងារផ្សេងទៀត ដែលប្រធានប្រគល់ជូន។

### ២- ភារកិច្ចរបស់សមាជិក

- អាននិក្ខេបបទលម្អិត វាយតម្លៃ និងផ្តល់ពិន្ទុ
- ផ្តល់នូវយោបល់ និងឆ្លើយតបតាមការស្នើសុំរបស់ប្រធាននិងបេក្ខជនបណ្ឌិត
- ចោទសួរសំណួរដល់បេក្ខជនទាក់ទងនឹងនិក្ខេបបទ
- ចូលរួមប្រជុំនានាតាមការអញ្ជើញរបស់ប្រធាន
- វាយតម្លៃ ផ្តល់ពិន្ទុលើនិក្ខេបបទសាកល្បងនិងការធ្វើបទបង្ហាញរបស់បេក្ខជនបណ្ឌិត
- ផ្តល់យោបល់កែលម្អដល់និក្ខេបបទសាកល្បង

- ចុះហត្ថលេខាលើរបាយការណ៍ការពារនិក្ខេបបទសាកល្បង
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់ប្រធានគណៈកម្មការ។

**៣- ភារកិច្ចរបស់ជំនួយការ**

- រៀបចំលិខិតអញ្ជើញគណៈកម្មការការពារនិក្ខេបបទសាកល្បង
- ធ្វើការទំនាក់ទំនងជាមួយសមាជិកគណៈកម្មការ
- រៀបចំឯកសាររួមមាន និក្ខេបបទ តារាងវាយតម្លៃដាក់ពិន្ទុ របាយការណ៍ លិខិតអញ្ជើញ ជូនដល់សមាជិកគណៈកម្មការទាំងអស់
- គ្រប់គ្រងបញ្ជីវត្តមានក្នុងពេលដំណើរការការពារនិក្ខេបបទសាកល្បង
- កត់ត្រានិងធ្វើរបាយការណ៍ស្តីពីការពារនិក្ខេបបទសាកល្បង
- អនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់ប្រធានគណៈកម្មការ។

ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា ថ្នាក់ដឹកនាំវិទ្យាស្ថានក្រោយបរិញ្ញាបត្រ គណៈកម្មការការពារនិក្ខេបបទសាកល្បង អង្គភាពចំណុះពាក់ព័ន្ធ និងបេក្ខជនបណ្ឌិត ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ២០២៥

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **ឯក មនោសែន**

កន្លែងទទួល :

- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- ថ្នាក់ដឹកនាំវិទ្យាស្ថានក្រោយបរិញ្ញាបត្រ
- គណៈកម្មការការពារនិក្ខេបបទសាកល្បង
- ឯកសារ កាលប្បវត្តិ